សូមគោរពឪពុកម្តាយ/អ្នកថែទាំ

ឧបត្តិហេតុដ៏តក់ស្លុតដែលបានកើតឡើងនាពេលថ្មីៗនេះ អាចប៉ះពាល់ដល់សិស្សសាលារបស់យើងដោយផ្ទាល់ ឬដោយប្រយោល។ គំនិតរបស់យើងគឺនៅជាប់ជាមួយក្រុមគ្រួសារ និងមិត្តភក្តិទាំងអស់ដែលបានរងផលប៉ះពាល់ដោយព្រឹត្តិការណ៍សោកនាដកម្មនេះ។

ថ្ងៃនេះ និងក្នុងរយៈពេលប៉ុន្មានសប្តាហ៍ខាងមុខនេះ អ្នក និងកូន/កូនៗរបស់អ្នកអាចរងផលប៉ះពាល់ក្នុងលំនាំផ្សេងៗគ្នា ដោយសារមនុស្សម្នាក់ៗនឹងមានប្រតិកម្មខុសៗគ្នា។ អ្នកខ្លះអាចនឹងមានអារម្មណ៍ខ្លាំង អ្នកខ្លះប្រហែលជាចង់និយាយ ខណៈពេលអ្នកខ្លះទៀតមិនចង់និយាយ។ ប្រតិកម្មអាចប្រែប្រួលតាមពេលវេលា ដែលជាការឆ្លើយតបធម្មតាចំពោះឧប្បត្តិហេតុបែបនេះ។ ខ្ញុំសូមលើកទឹកចិត្តអ្នកឱ្យអនុញ្ញាតកូន/កូនៗរបស់អ្នកដឹងថាអ្នកនៅទីនោះដើម្បីស្តាប់កង្វល់របស់ពួកគេ គ្រប់ពេលដែលពួកគេចង់ចែករំលែកពីកង្វល់ទាំងនោះ។

សារសំខាន់ពីរដើម្បីផ្សព្វផ្សាយជាមួយកុមារ និងមនុស្សវ័យក្មេងគឺ៖

- យើងទាំងអស់គ្នាគួរតែស្វែងរកជំនួយពីអ្នកដ៏ទៃ នៅពេលដែលយើងមានអារម្មណ៍ធ្លាក់ចុះ ឬងាយរងគ្រោះ។
- វាជារឿងសំខាន់ក្នុងការប្រាប់មនុស្សពេញវ័យដែលគួរឱ្យទុកចិត្ត ប្រសិនបើអ្នកព្រួយបារម្ភអំពីមិត្តភក្តិ ឬខ្លួនអ្នក។

សម្រាប់ព័ត៌មានបន្ថែម សូមមើលខិត្តប័ណ្ណផ្សព្វផ្សាយដែលភ្ជាប់មកជាមួយ 'ការជួយកុមារ និងមនុស្សវ័យក្មេងទប់ទល់នឹងព្រឹត្តិការណ៍ដ៏តក់ស្លុត'។ យើងសូមលើកទឹកចិត្តឱ្យអ្នកចូលប្រើប្រាស់សេវាកម្មណាមួយដែលបានរាយបញ្ជី ប្រសិនបើតម្រូវការកើតឡើង។

មានជម្រើសផ្សេងៗសម្រាប់ការគាំទ្របន្ថែមទៀតដែលអាចមាននៅសាលារៀនរបស់យើង រួមមានការគាំទ្រពីបុគ្គលិកប្រឹក្សាសាលាផងដែរ។ សូមទាក់ទងនាយកសាលារបស់កូនអ្នក ដើម្បីស្វែងរកជំនួយបន្ថែមសម្រាប់កូនរបស់អ្នក ប្រសិនបើតម្រូវ។

ប្រសិនបើអ្នកត្រូវការជំនួយអ្នកបកប្រែផ្ទាល់មាត់ដើម្បីទាក់ទងមកសាលារៀន សូមហៅទូរសព្ទលេខ 131 450 ប្រាប់ការីទូរសព្ទនូវភាសាដែលអ្នកត្រូវការ ហើយស្នើសុំឱ្យពួកគេទូរសព្ទទៅសាលារៀន។ ការីទូរសព្ទនឹងរៀបចំអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ ដើម្បីជួយក្នុងការសន្ទនារបស់អ្នក។ គេនឹងមិនគិតថ្លៃសេវានេះពីអ្នកទេ។

ដោយការគោរពដ៏ស្មោះ

នាយកសាលា